ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ...០៥...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការប្រែក្លាយ ពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ទៅជា ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងធម្មការ និងសាសនា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

**ស ម្រេ ច**

**មាត្រា ១.-**

ប្រែក្លាយពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ទៅជាពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ (PREAH SIHANOUK RAJA BUDDHIST UNIVERSITY) ហៅកាត់ជាភាសាខ្មែរ "ព.ស.ស" និងហៅកាត់ជាភាសាអង់គ្លេស "PSRBU" ។ ពុទ្ធិកសាកលវិទ្យាល័យនេះ ស្ថិតនៅក្រោមឱវាទ របស់ក្រសួងធម្មការ និងសាសនា ។

**មាត្រា ២.-**

ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ មានតួនាទី និងភារកិច្ចអប់រំ បណ្តុះបណ្តាលសមណនិស្សិត និងនិស្សិត សិក្សាស្រាវជ្រាវ ពុទ្ធសាសនា និងសាសនាឯទៀត វប្បធម៌ អក្សរសាស្ត្រ និងវិទ្យាសាស្ត្រសង្គម ។

**មាត្រា ៣.-**

ចំពោះមុខ ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ ធ្វើការបណ្តុះបណ្តាល កម្រិតបរិញ្ញាបត្ររង បរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់។ កម្មវិធីសិក្សា ត្រូវមានការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៤.-**

ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ ដឹកនាំដោយសាកលវិទ្យាធិការមួយរូប ជាមន្ត្រីសង្ឃ ដែលមានសញ្ញាបត្រយ៉ាងទាប កម្រិតបរិញ្ញាបត្រជាន់ខ្ពស់ និងសាកលវិទ្យាធិការរងមួយរូប ឬច្រើនរូប ជាជំនួយការ ដែលជាមន្ត្រីសង្ឃ ឬជាគ្រហស្ថ ។

**មាត្រា ៥.-**

តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ របស់ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ ត្រូវកំនត់ ដោយប្រកាស របស់ក្រសួងធម្មការ និងសាសនា ។

**មាត្រា ៦.-**

ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ មានមហាវិទ្យាល័យ និងមជ្ឈមណ្ឌល ដូចខាងក្រោម :

- ពុទ្ធិកមហាវិទ្យាល័យទស្សនវិជ្ជា និងសាសនា
- ពុទ្ធិកមហាវិទ្យាល័យវិទ្យាសាស្ត្រអប់រំ និងព័ត៌មានវិទ្យា
- ពុទ្ធិកមហាវិទ្យាល័យអក្សរសាស្ត្រ
- ពុទ្ធិកមហាវិទ្យាល័យបាលី-សំស្ក្រឹត និងភាសាបរទេស
- ពុទ្ធិកមជ្ឈមណ្ឌលត្រៃកោសល្យ

ទៅអនាគត ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ អាចមានមហាវិទ្យាល័យ ឯកទេស សាខា ឬពង្រីកកម្រិត ឬប្រភេទបណ្តុះបណ្តាលផងទៀត ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៧.-**

សមណនិស្សិត និងនិស្សិតដែលរៀនចប់កម្មវិធីសិក្សា របស់ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ និងទទួលបានជោគជ័យ ក្នុងការប្រលងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាបត្រតាមកម្រិត និងតាមឯកទេស ដែលបានសិក្សា ។ សញ្ញាបត្រនេះ ផ្តល់ឱ្យដោយពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ ហើយត្រូវបានទទួលស្គាល់ ពីក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណីពុទ្ធិកសាកលវិទ្យាល័យនេះ បានបំពេញ និងអនុវត្ត តាមគោលការណ៍ និងបទដ្ឋាន របស់ក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៨.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការ នៃក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព តាមភារកិច្ចរៀងខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មករា ឆ្នាំ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួលៈ
- ខុទ្ទកាល័យសម្តេចព្រះសង្ឃរាជទាំងពីរគណៈ
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និង ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលាក្រុងភ្នំពេញ
- ដូចមាត្រា ៩
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ